**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៤)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារ ខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២៣ នៃរោងចក្រ ទាំង២៣ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ នាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង២៣ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១៧ ខែ[illegible] ឆ្នាំ២០២៣**

**បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ**

**ចំនួន ២៣ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 23 |
| 1 | ក្រុមហ៊ុន ជេអេស លេឌើរ ខលលិកសិន ភ្នំពេញ ឯ.ក រោងចក្រទី២ | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ជេអេស លេឌើរ ខលលិកសិនភ្នំពេញ ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ហេន7 ហ្គាមិនឯក (ទីតាំងពោធិ៍សែនជ័យ) | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហេន ស៊េវេន អឺភែរឹល | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហ្វជូណា អ៊ិនធើណេសិនណល(ខេមបូឌា) អ៊ិនដាសស្ទ្រី ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន យ៉ុងដេវ៉ី ហ្គាមេន ភីធីវ៉ាយ អិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ម៉នីងគ្លរី ហ្គាមេន អ៊ិនធើប្រាយ ខូអិលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុន អប្សរា ហ្គាមេន ខូអិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន វី.ធី ហ្គាម៉ិន អេកសេសិរី ខូ អិលធីឌី | ភ្នំពេញ |
| 10 | ក្រុមហ៊ុន អ៊ីអឹមប៊ី ដែលគូវី (ខេមបូឌា)ខូ.,អិលធីឌី | ភ្នំពេញ |
| 11 | ក្រុមហ៊ុន សើង យ៉ុង ហ្គាមែនហ្វាត់តូរី ខូអិលធីឌី | ភ្នំពេញ |
| 12 | ក្រុមហ៊ុន គូនយូ ធូល ប៉ែក (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 13 | ក្រុមហ៊ុន ញូអេសថ៍ ហ្គាម៉ិន (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 14 | ក្រុមហ៊ុន ស៊ីណូប្រៅដ៏ អឹភែរឹល (ខេមបូឌា) ឯ.ក | កណ្តាល |
| 15 | ក្រុមហ៊ុន ហូលលីវ៉េល ហ៊ែនប៉ែក មេនូហ្វេកឆឺរីង | កណ្តាល |
| 16 | ក្រុមហ៊ុន ហ៊ែនថុន ឡាក់ហ្គេដ (ខេមបូឌា) ឯ ក | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន ហ្វ៊ូតហ្វ៊ូរវើត (ខេមបូឌា) សកខ៍ | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន វ៉េត ម៉ាស ហ្គាម៉ិន (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ស្រ្តេត ប្រដាក់សិន ហ្គាម៉ិន ឯ.ក | តាកែវ |
| 20 | ក្រុមហ៊ុន មេតថេក (ខេបូឌា) ខប លីមីធីត | កំពង់ចាម |
| 21 | ក្រុមហ៊ុន យីងម៉េកយើ(ខេមបូឌា)ហ្វូតវែរ ខូអិលធីឌី. | ស្វាយរៀង |
| 22 | ក្រុមហ៊ុន ស៊ីគូ (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 23 | ក្រុមហ៊ុន តៃអ៊ីហ្សឺ អ៊ិនធឺណាស្យិនណលខូ.,អិលធីឌី | ពោធិ៍សាត់ |